**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១២)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតដែលបានព្យួរកិច្ចសន្យាការងារក្នុងខែកញ្ញា ខែតុលា និងខែវិច្ឆិកា ឆ្នាំ២០២៣ នៃរោងចក្រ ទាំង៣៣ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង៣៣ នេះ មិនបានទទួលសារទូរសព្ទពីធនាគារវីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ... ខែ ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០២៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១ ខែ[illegible] ឆ្នាំ២០២៣
បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ
ចំនួន ៣៣ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 33 |
| 1 | ក្រុមហ៊ុន នីវ ហ្គេង ឌី (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ហ្វៃរជុង (ខេមបូឌា) លីមីធីត | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ហ្វជូណា អ៊ិនធើណេសិនណល(ខេមបូឌា) អ៊ិនដាសស្រ្ទី ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន អប្សរា ហ្គាមេន ខូអិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ហាយ សេង 168(ខេមបូឌា)ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន អេ ខេ អិម ហ្គាមេន | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ស្កាយវើតហ្វេសសិន (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ហាត អ៊ិនធើប្រាយ(ខេមបូឌា)ខូអិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ហ្គ្រេត យូញៀន(ខេមបូឌា)ហ្គាមេនខូអិលធីឌី | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ម៉ាស្ទ័រ&ហ្វ្រេង(ខេមបូឌា)ខូអិលធីឌី | កណ្តាល |
| 11 | ក្រុមហ៊ុន ហប ឡុក (ខេមបូឌា) ឯ.ក | កណ្តាល |
| 12 | ក្រុមហ៊ុន សេលលី ហ្វេសិន ហ្គាម៉ិន ហ្វេកធើរី ឯ.ក | កណ្តាល |
| 13 | ក្រុមហ៊ុន ដឹ សួល ហ្គៀ (ខេមបូឌា) ឯ.ក | កណ្តាល |
| 14 | ក្រុមហ៊ុន ហ្គ្រេត បេសវ៉េ មេនញូហ្វេកឈើរីង ឯ.ក | កណ្តាល |
| 15 | ក្រុមហ៊ុន យូនីត (ខេមបូឌា) ខូ.,អេលធីឌី | កណ្តាល |
| 16 | ក្រុមហ៊ុន អេវ៉ាយស៊ី ហ្គាម៉ិន ហ្វេកធើរី ឯ.ក | កណ្តាល |
| 17 | ក្រុមហ៊ុន មូនតៃ ខេជេ (ខេមបូឌា) ខូអិលធីឌី | កណ្តាល |
| 18 | ក្រុមហ៊ុន វ៉ាសាន់ អេចខេ ហ្វេកធើរី (ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន(ខេបូឌា)ខូអិលធីឌី | កំពង់ស្ពឺ |
| 20 | ក្រុមហ៊ុន ស៊ូតៀល (ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 21 | ក្រុមហ៊ុន ហ្វ៊ូតហ្វ៉រវើត (ខេមបូឌា) សកខ៍ | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុន ឆាយណាសូហ៊ែនប៉ែក ឯ.ក | កំពង់ស្ពឺ |
| 23 | ក្រុមហ៊ុន ធីនីនស្ទូឡឹ អ៊ីកែវីល អ៊ិនធើណេសិនណល លីមីធីត | កំពង់ស្ពឺ |

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| 24 | ក្រុមហ៊ុន សាន់វ៉ាយ ហ្វេសិន(ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 25 | ក្រុមហ៊ុន វីនក្រោន (ខេមបូឌា) អិនដាសស្ទ្រៀល ឯ ក | កំពង់ស្ពឺ |
| 26 | ក្រុមហ៊ុន ស៊ីអេសហ្គោលវ៉េ ថេកស្តាយ (ខេមបូឌា)ខូអិលធីឌី | តាកែវ |
| 27 | ក្រុមហ៊ុន លីនគុន មេនូហ្វេកឆឺរីង ឯ.ក | តាកែវ |
| 28 | ក្រុមហ៊ុន អ៊ី-ចេង (ខេមបូឌា) ខបភើរេសិន | តាកែវ |
| 29 | ក្រុមហ៊ុន ឡុង ឈឹង ស៊ូ ផាត ឯ.ក | កំពង់ចាម |
| 30 | ក្រុមហ៊ុន ម៉ាន់ ឡុង ស៊ូ ឯ .ក | កំពង់ចាម |
| 31 | ក្រុមហ៊ុន វ៉ាំឡុង (ខេមបូឌា) ហ្វ៊ូតវែរ អ៊ីនដាសស្ទ្រី ឯ.ក | កំពង់ចាម |
| 32 | ក្រុមហ៊ុន ឆាងហួយ (ខេមបូឌា) ហ៊ែនប៊ែកអឹមអេហ្វឯ.ក | កំពង់ឆ្នាំង |
| 33 | ក្រុមហ៊ុន ខេមបូឌាន សាន់វ៉ាយ៍ ហ្គាមេន ខូអិលធីឌី | ព្រះសីហនុ |